ក្រសួងសុខាភិបាល នៃ Minnesota Department of Health

# ការព្យាបាល រោគរបេងមិនទាន់ចេញមុខ

ការពិសោធន៍រោគរបស់អ្នកបង្ហាញឲ្យឃើញ ថាអ្នកមានឆ្លងរោគរបេងមិនទាន់ចេញមុខ ដែលភាសាអង់គ្លេសហៅថា Latent TB Infection ឬហៅកាត់ថា "LTBI "។ មេរោគរបេងមួយចំនួនតូចបានឆ្លងទៅផ្នែក(អវយវៈ)ជាច្រើននៃខ្លួនប្រាណរបស់អ្នក ដូចជាសួត ឆ្អឹង ឬវក្កំ(ដំរងនោម)របស់អ្នក ។

មេរោគរបេងឥឡូវនេះមិនទាន់ធ្វើទុក្ខអ្នកទេ ។ វាកំពុងតែ "ដេកលក់" ប៉ុន្តែវាមានជីវិតរស់នៅជាដដែល ។ មេរោគរបេងនឹង "ដេកលក់" ដរាបណារូបកាយរបស់អ្នកអាចតយុទ្ធទាស់នឹងវាបាន ។ នៅពេលណាអ្នកមាន LTBI នោះអ្នកមិនអាចចំឡងរោគរបេងទៅមនុស្សផ្សេងៗទៀតបានឡើយ ។

បើរូបកាយរបស់អ្នកឈប់តយុទ្ធនឹងមេរោគរបេង នោះវានឹង "ភ្ញាក់" ហើយក៏ចាប់ផ្តើមដុះដាលឡើង ។ **ការនេះអាចកើតឡើងចំពោះមនុស្សគ្រប់ៗរូបដែលមាន LTBI នៅពេលណាមួយ ។** កាលបើមេរោគដុះដាលឡើង ហើយឆ្លងរាលដាល នោះគេហៅថា "រោគរបេងសកម្ម" ។ មនុស្សដែលមានរោគរបេងសកម្ម អាចឈឺថ្កាត់យ៉ាងខ្លាំង ហើយអាចចំឡងរោគរបេងទៅអ្នកដទៃ។

## តើខ្ញុំអាចការពាររោគរបេងសកម្ម ដោយរបៀបណា?




សព្វថ្ងៃនេះមានថ្នាំពេទ្យជាច្រើន ដែលអ្នកអាចលេបបាន ដើម្បីការពារអ្នកកុំឲ្យមានរោគរបេងសកម្ម ។ ថ្នាំឈ្មោះ Isoniazid (INH) គឺជាថ្នាំធម្មតាម្យ៉ាងដែលបានប្រើសំរាប់ព្យាបាល LTBI ។ ថ្នាំ INH នឹងសំឡាប់មេរោគរបេងដែលកំពុងតែ "ដេកលក់" **មុននឹង**វាមានឱកាសធ្វើឲ្យអ្នកឈឺថ្កាត់ ។ ពីព្រោះតែមេរោគរបេងខ្លាំងរឹងរុស ម្ល៉ោះហើយវានឹងប្រើពេលជាច្រើនខែ ទំរាំថ្នាំពេទ្យអាចសំឡាប់មេរោគរបេងបាន ។

ថ្នាំ INH មានប្រសិទ្ធិភាពយ៉ាងល្អ បើសិនជាអ្នកលេបវាជារៀងរាល់ថ្ងៃ រហូតទាល់តែគ្រូពេទ្យរបស់អ្នក ប្រាប់អ្នកថាអ្នកអាចឈប់លេបវាទៀត ។ ត្រូវកុំលេបថ្នាំ INH របស់អ្នកជាមួយម្ហូប ។

អ្នកគួរតែទៅជួបអ្នកផ្តល់ការថែរក្សាសុខភាពរបស់អ្នកមួយខែម្តង ក្នុងកាលដែលអ្នកកំពុងតែលេបថ្នាំ INH ដើម្បីឲ្យប្រាកដថាការព្យាបាលរបស់អ្នកកំពុងតែមានដំណើរយ៉ាងល្អ ។

## តើហេតុអ្វីបានជាខ្ញុំត្រូវលេបថ្នាំ បើខ្ញុំពុំមានការឈឺថ្កាត់ផងនោះ?

ថ្នាំ INH នឹងសំឡាប់មេរោគរបេងនៅក្នុងរូបកាយរបស់អ្នក **មុននឹង**វាមានឱកាស "ភ្ញាក់" ពីដេក ហើយធ្វើឲ្យអ្នកឈឺថ្កាត់ ។ សូមចាំថា មេរោគរបេងងាយនឹងសំឡាប់បានស្រួលជាង ក្នុងកាលដែលវាកំពុងតែ "ដេកលក់" ។

## តើហេតុអ្វីបានជាខ្ញុំគួរគប្បីដឹង អំពីថ្នាំសំរាប់ LTBI?

មនុស្សជាច្រើនដែលលេបថ្នាំ INH ជារៀងរាល់ថ្ងៃ គឺពុំមានបញ្ហាអ្វីឡើយ ក៏ប៉ុន្តែ**មានការខ្លះដែលអ្នកគួរតែឃ្លាំមើល :**

- មានគ្រុនក្តៅលើសពីចំនួនបីថ្ងៃ
- មិនសូវឃ្លានអាហារ ស្រកទំងន់ ឬអស់កំឡាំងកំហែង ដោយគ្មានមូលហេតុអ្វីសោះ
- មានរមួលពោះ ឬក្អួតចង្អោរ :
  មនុស្សខ្លះមានរមួលពោះបន្តិចបន្តួច នៅពេលគេ**ចាប់ផ្តើម**លេបថ្នាំ INH ។ បើមានការនេះកើតឡើងដល់អ្នក សូមព្យាយាមបរិភោគអាហារ**បន្តិចបន្តួច** នៅពេលលេបថ្នាំរបស់អ្នក ឬលេបវានៅពេលចូលដំណេក ។ **បើអ្នកនៅតែរមួលពោះជាដដែលបន្ទាប់ពីបីថ្ងៃក្រោយមក នោះត្រូវទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នកជាបន្ទាន់ ។**
- មានឈឺក្នុងដំបារពោះរបស់អ្នក
- មានទឹកនោមស្រអាប់ (ពណ៌ទឹកតែ ឬទឹកកាហ្វេ)
- មានលឿងស្បែក ឬលឿងភ្នែក
- មានកន្ទួលស្បែក ឬរមាស់
- មានស្ពឹកស្រពន់ ឬឈឺឆៀបៗនៅដៃ ឬនៅប្រអប់ជើងរបស់អ្នក
- មានក្អកលើសពីចំនួនបីអាទិត្យ
- បែកញើសនៅពេលយប់

**បើអ្នកមានបញ្ហាអ្វីមួយទាំងនេះ សូមទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នកជាបន្ទាន់ –សូមកុំរង់ចាំដល់ពេលណាត់ជួបនៅលើកក្រោយឲ្យសោះ ។**

### ចំណុចសំខាន់ផ្សេងៗទៀត :

- **ការផឹកស្រា** នៅពេលអ្នកលេបថ្នាំ INH អាចបណ្តាលឲ្យឈឺថ្លើមរបស់អ្នក ។ ចូរកុំផឹកស្រាបៀរ ស្រាស ឬគ្រឿងស្រវឹងអ្វីទៀតឲ្យសោះ រហូតទាល់តែការព្យាបាល LTBI របស់អ្នកបានចប់ ។
- បើអ្នកមានលេប**ថ្នាំពេទ្យអ្វីផ្សេងទៀត** ឬបើអ្នកកំពុងតែ**មានផ្ទៃពោះ** នោះត្រូវតែកុំភ្លេចប្រាប់គ្រូពេទ្យរបស់អ្នកឲ្យសោះ ។

# ការព្យាបាល រោគរបេងមិនទាន់ចេញមុខ ទំព័រទី ២

## បើសិនជាខ្ញុំមិនលេបថ្នាំ តើមានអ្វីកើតឡើង?

បើអ្នកមិនលេបថ្នាំ INH របស់អ្នក ឬបើអ្នកឈប់លេបថ្នាំរបស់អ្នករហ័សពេក នោះអ្នកនឹងឈឺថ្កាត់ដោយសាររោគរបេងសកម្មហើយ ។ ការនេះអាចកើតឡើងចំពោះ**មនុស្សណាម្នាក់** ដែលមាន LTBI **នៅពេលណាមួយជាពុំខាន** ។ ចូរកុំរង់ចាំឲ្យការនេះបានកើតឡើងដល់អ្នក និងគ្រួសាររបស់អ្នក ឲ្យសោះ!

## តើខ្ញុំគួរតែធ្វើអ្វីខ្លះ បើសិនជាខ្ញុំបានចាក់ថ្នាំ BCG ជាបង្ការ?

នៅប្រទេសជាច្រើនដែលមានកើតរោគរបេង នោះមានមនុស្សជាច្រើនបានចាក់ថ្នាំបង្ការម្យ៉ាងគេហៅថា BCG ។ ថ្នាំ BCG អាចការពារក្មេងៗកុំឲ្យកើតរោគរបេង ប៉ុន្តែវាមានប្រសិទ្ធិភាពតែពីរបីឆ្នាំប៉ុណ្ណោះ ។

មនុស្សទាំងឡាយណាដែលបានចាក់ថ្នាំ BCG ជាបង្ការ ក៏អាចឆ្លងរោគរបេងសកម្មបានដែរ! បើអ្នកបានចាក់ថ្នាំ BCG ជាបង្ការក្តី គង់តែអ្នកនៅអាចការ-ពារខ្លួនអ្នកបានដែរ ដោយលេបថ្នាំសំរាប់ LTBI ។

## ចុះបើសិនជាខ្ញុំគ្មានប្រាក់កាសគ្រប់គ្រាន់ ដើម្បីបង់ថ្លៃថ្នាំពេទ្យ តើវាជាយ៉ាងណាទៅ?

សូមសាកសួរគ្រូពេទ្យ ឬពេទ្យរបស់អ្នក អំពីការទទួលថ្នាំរបេងជាទទេពីក្រសួងសុខាភិបាលរដ្ឋមីនីសូតា ។

## ចុះបើសិនជាខ្ញុំផ្លាស់ទីលំនៅ?

បើអ្នកផ្លាស់ទីលំនៅ ទៅនៅរដ្ឋ ឬទីក្រុងដទៃទៀត នោះត្រូវប្រាប់អ្នកផ្តល់ការថែរក្សាសុខភាពរបស់អ្នក **មុននឹងអ្នកប្តូរទីកន្លែង** ដ្បិតគេអាចជួយអ្នកធ្វើឲ្យប្រាកដថាអ្នកទទួលថ្នាំរបេងរបស់អ្នក បន្ទាប់ពីអ្នកផ្លាស់ទីលំនៅ ។

**ការពារខ្លួនអ្នក ការពារគ្រួសាររបស់អ្នក និងការពារ**
**មិត្រភ័ក្តិរបស់អ្នក កុំឲ្យឆ្លងរោគរបេង**
**–ដោយលេបថ្នាំរបេងរបស់អ្នកឲ្យអស់!**

## តើធ្វើដូចម្តេច ឲ្យខ្ញុំនឹកចាំលេបថ្នាំរបេងរបស់ខ្ញុំ បានទៅ?

**វាមានសារៈសំខាន់ណាស់ ដែលអ្នកលេបថ្នាំ INH របស់អ្នកជារៀងរាល់ថ្ងៃ ។** បើអ្នកខានលេបជាច្រើនថ្ងៃ ថ្នាំពេទ្យអាចនឹងគ្មានប្រសិទ្ធិភាពទេ ។ អ្នកត្រូវតែលេបវាជានិច្ច រហូតទាល់តែគ្រូពេទ្យរបស់អ្នក ប្រាប់អ្នកថាអ្នកអាចឈប់លេបវាទៀត ។

ខាងក្រោមនេះគឺជាមធ្យោបាយខ្លះ ដែលជួយឲ្យអ្នកនឹកចាំបាន :

- ទុកថ្នាំរបស់អ្នក នៅកន្លែងណាមួយដែលអ្នកអាចមើលវាឃើញជារៀងរាល់ថ្ងៃ ។
- ប្រាប់សមាជិកគ្រួសារ ឬមិត្រភ័ក្តិ ឲ្យរំលឹកអ្នកជារៀងរាល់ថ្ងៃ ។
- កត់ចំណាំនៅលើប្រក្រតិទិនរបស់អ្នកជារៀងរាល់ថ្ងៃ បន្ទាប់ពីអ្នកបានលេបថ្នាំរបស់អ្នក ។
- ប្រើប្រអប់រំលឹកការលេបថ្នាំ ។
- លេបថ្នាំរបស់អ្នកនៅពេលដូចៗគ្នាជារៀងរាល់ថ្ងៃ ។ ឧទាហរណ៍ : នៅពេលបន្ទាប់ពីអ្នកដុសធ្មេញរបស់អ្នក បន្ទាប់ពីការស្រស់ស្រូបអាហារពេលព្រឹករួច ឬគ្រាន់តែនៅមុនពេលអ្នកចូលដំណេក ។

បើអ្នកខានលេបថ្នាំនៅថ្ងៃណាមួយ សូមសរសេរកត់វាទុក ប្រយោជន៍ឲ្យអ្នកអាចប្រាប់គ្រូពេទ្យ ឬពេទ្យរបស់អ្នក នៅពេលអ្នកទៅជួបពិនិត្យនៅលើកក្រោយ ។

**ឈ្មោះមន្ទីរពិនិត្យរោគា /គ្រូពេទ្យ /ពេទ្យ របស់អ្នក**

________________________________

________________________________

________________________________

**លេខទូរស័ព្ទ #:** ________________________

MINNESOTA MDH DEPARTMENT OF HEALTH
Tuberculosis Prevention and Control Program
P.O. Box 64975
St. Paul, MN 55164-0975
651-201-5414
1-877-676-5414
www.health.state.mn.us/tb

5/2004